បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 17 ខែ 06 ឆ្នាំ 2003

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

១៧-៦-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៦០១/២០៤ តែងតាំងឯកឧត្តម **អ៊ុង ខេង** ជាសមាជិក នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ១៥១៧

២២-៦-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៦០១/២០៧ តែងតាំងលោកឧត្តមសេនីយ៍ត្រី **សែម សុវណ្ណនី** ជាឧកញ៉ា ១៥១៨

២២-៦-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៦០១/២០៨ តែងតាំងលោកស្រី**ចាន់ សុន្ធា** ជាឧកញ៉ា ១៥១៩

## II រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ

១៩-៦-២០០១ -អនុក្រឹត្យលេខ ៥០ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១៥១៩

២១-៦-២០០១ -អនុក្រឹត្យលេខ ៥១ អនក្រ.បក ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ១៥២១

២១-៦-២០០១ -អនុក្រឹត្យលេខ ៥២ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១៥៣២

២២-៦-២០០១ -អនុក្រឹត្យលេខ ៥៣ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១៥៣២

២០-៦-២០០១ -អនុក្រឹត្យលេខ ២៥២ ស្តីពីការជូនមេដាយការងារ ១៥៣៥

២១-៦-២០០១ -អនុក្រឹត្យលេខ ២៥៣ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៥៣៩

២១-៦-២០០១ -អនុក្រឹត្យលេខ ២៥៤ អនក្រ.តត ស្តីពីការជូនមេដាយសុត្ថាភា ១៥៤០

២១-៦-២០០១ -អនុក្រឹត្យលេខ ២៥៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥៤១

| | | |
|---|---|---|
| ២១-៦-២០០១ | -អនុក្រឹត្យលេខ ២៥៦ អនក្រ.តត ស្តីពីការជូនមេដាយសុត្ថារា | ១៥៤២ |
| ២១-៦-២០០១ | -អនុក្រឹត្យលេខ ២៥៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៥៤៣ |
| ២១-៦-២០០១ | -អនុក្រឹត្យលេខ ២៥៨ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ១៥៤៤ |
| ២១-៦-២០០១ | -អនុក្រឹត្យលេខ ២៥៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៥៤៦ |
| ២១-៦-២០០១ | -អនុក្រឹត្យលេខ ២៦០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៥៤៧ |
| ២១-៦-២០០១ | -អនុក្រឹត្យលេខ ២៦១ អនក្រ.តត ស្តីពីការជូនមេដាយសុត្ថារា | ១៥៤៨ |
| ២១-៦-២០០១ | -អនុក្រឹត្យលេខ ២៦២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៥៤៩ |
| ២១-៦-២០០១ | -អនុក្រឹត្យលេខ ២៦៣ អនក្រ.តត ស្តីពីការជូនមេដាយមុនិសារាភ័ណ្ឌ | ១៥៥០ |
| ២១-៦-២០០១ | -អនុក្រឹត្យលេខ ២៦៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៥៥១ |
| ២១-៦-២០០១ | -អនុក្រឹត្យលេខ ២៦៥ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ | ១៥៥២ |
| ...-៦-២០០១ | -អនុក្រឹត្យលេខ ២៦៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៥៥៣ |
| ...-៦-២០០១ | -អនុក្រឹត្យលេខ ២៦៧ អនក្រ.តត ស្តីពីការជូនមេដាយមុនិសារាភ័ណ្ឌ | ១៥៥៤ |
| ២២-៦-២០០១ | -អនុក្រឹត្យលេខ ២៦៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៥៥៥ |
| ២២-៦-២០០១ | -អនុក្រឹត្យលេខ ២៦៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៥៥៦ |


## ២-សេចក្តីសំរេច


| | | |
|---|---|---|
| ១៩-៦-២០០១ | -សេចក្តីសំរេចលេខ ៣៣ សសរ ស្តីពីការធ្វើវិសោធនកម្មលើសេចក្តីសំរេចលេខ ០៧ សសរ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០១ | ១៥៥៧ |
| ១៩-៦-២០០១ | -សេចក្តីសំរេចលេខ ៣៤ សសរ ស្តីពីការបង្កើតក្រុមការងារដើម្បីសិក្សាលើការរៀបចំកសាងកំពង់ផែទេសចរណ៍នៅខេត្តសៀមរាប | ១៥៦០ |
| ២១-៦-២០០១ | -សេចក្តីសំរេចលេខ ៣៥ សសរ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ | ១៥៦២ |
| ២២-៦-២០០១ | -សេចក្តីសំរេចលេខ ៣៦ សសរ ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យ និងស្រាវជ្រាវករណីមិនប្រក្រតីដែលពាក់ព័ន្ធទៅនឹងការអនុវត្តន៍ការងារដំឡើនមន្ត្រីរាជការជាពិសេសការអនុវត្តន៍តារាងទូទាត់បៀវត្សតាមប្រព័ន្ធពតិមានវិទ្យានៅក្រសួងសុខាភិបាល | ១៥៦៥ |

# III-ការិយាល័យបណ្តាក្រសួង

## ១-ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

### ប្រកាស


| | | |
|---|---|---|
| ១៩-៦-២០០១ | -ប្រកាសលេខ ១៩៥ បទ.ប្រក ស្តីពីការរៀបចំ និងការគ្រប់គ្រងប្រព័ន្ធ និងសេវាកម្ម អ៊ិនធឺណែត ( INTERNET ) និងប្រភេទសេវា VOIP នៅព្រះរាជាណាចក្រកម្ពុជា | ១៥៦៧ |
| ២០-៦-២០០១ | -ប្រកាសលេខ ១៩៧ បទ.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៥៦៩ |
| ២១-៦-២០០១ | -ប្រកាសលេខ ១៩៩ បទ.ប្រក ស្តីពីការបង្កើតមជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និងប័ណ្ណស័ព្ទ | ១៥៧០ |


## ២-ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងធម្មការនិងសាសនា

### សេចក្តីសំរេច


| | | |
|---|---|---|
| ២១-៦-២០០១ | -សេចក្តីសំរេចលេខ ១៦០ កធស.ប្រក អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំសាសនាគ្រិស្តឈ្មោះ " សេវេនដាយអាត់វេនទីស្ទ ចំបក់ហែ " ស្ថិតនៅភូមិចំបក់ហែ ឃុំពួក ស្រុកពួក ខេត្តសៀមរាប | ១៥៧២ |
| ២១-៦-២០០១ | -សេចក្តីសំរេចលេខ ១៦១ កធស.ប្រក អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំសាសនាគ្រិស្តឈ្មោះ " សេវេដាយអាត់វេនទីស្ទ កោះកុង " ស្ថិតនៅភូមិ ៣ ឃុំស្មាចមានជ័យ ស្រុកស្មាច់មានជ័យ ខេត្តកោះកុង | ១៥៧៣ |
| ២១-៦-២០០១ | -សេចក្តីសំរេចលេខ ១៦២ កធស.ប្រក អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " សេវេដាយ អាត់វេនទីស្ទអង្គតាសោម " ស្ថិតនៅភូមិ អង្គតាសោម ឃុំ អង្គសោម ស្រុកត្រាំកក់ ខេត្តតាកែវ | ១៥៧៥ |
| ១៧-៦-២០០១ | -ប្រកាសលេខ ២០៤ ប្រក.សក.បធ ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៥៧៦ |

**មាត្រា ២ .-** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ផ្គត់ផ្គង់ឯកសណ្ឋាន និង គ្រឿងបន្ទាប់បន្សំនៃសំលៀកបំពាក់ កងជីវពល ឆ្នាំ ២០០១ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

**បានយកសេចក្តីជំរាបជូន**

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

===

**អនុក្រឹត្យលេខ ៥១ អនក្រ.បក**

**ស្តីពីការធ្វើវិសោធនកម្មលើ**

**អនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧**

**ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ**

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខា ធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

-តាមសំណើរបស់ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សំរេច

**មាត្រា តែមួយ .-**

មាត្រា ៣ ៦ ១១ ១២ ១៣ ១៤ ១៥ ១៦ ១៧ ១៨ ១៩ ២០ ២១ ២២ ២៣ និង ២៤ ក្នុងជំពូក ២ ៤ ៥ ៦ ៧ ៨ និង ៩ នៃអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទត្រូវបានកែប្រែ និងបន្ថែម ដូចតទៅ :

## ជំពូក ២

## បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា ៣.- ថ្មី**

ក្រសួងអភិវឌ្ឍន៍ជនបទមានមុខងារ និងភារកិច្ចដូចតទៅ :

-កំណត់គោលនយោបាយ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ជនបទ ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។

-លើកទិសដៅ ផែនការរយៈពេលខ្លី មធ្យម និងវែង លើការងារអភិវឌ្ឍន៍ជនបទដើម្បីកែលំអស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រជារាស្ត្រជនបទទូទៅដោយរួមបញ្ចូលទាំងជនជាតិភាគតិចក្នុងព្រះរាជាណាចក្រកម្ពុជា អោយកាន់តែល្អប្រសើរឡើង កាត់បន្ថយជាបណ្ដើរៗនូវភាពក្រីក្រ និងភាពខុសគ្នារវាងអ្នកជនបទ និងអ្នកទីក្រុង ។

-ចូលរួមក្នុងការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិក្នុងវិស័យអភិវឌ្ឍន៍ជនបទ ដោយក៏រិតសកម្មភាពការងារត្រឹមថ្នាក់គ្រួសារ ភូមិ និងឃុំ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

-សិក្សាស្រាវជ្រាវ ប្រមូលផ្តុំ និងគ្រប់គ្រងទិន្នន័យ ពត៌មាន ស្ថិតិ អំពីស្ថានភាព សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ដោយគិតទាំងតំបន់ភ្នំ តំបន់ខ្ពង់រាប និងតំបន់វាលរាប ។

-អភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលបច្ចេកទេសជំនាញ និងចំណេះដឹងដល់មន្ត្រី បុគ្គលិករាជការរបស់ក្រសួង ។

-រៀបចំបើកមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈថ្នាក់ភូមិភាគដល់ប្រជារាស្ត្រជនបទតាមការចាំបាច់ និងតាមលទ្ធភាពជាក់ស្តែង ។

-អប់រំ ផ្សព្វផ្សាយ ដើម្បីលើកកំពស់ផលិតភាព និងប្រាក់ចំណូលប្រចាំគ្រួសាររបស់ប្រជាពលរដ្ឋ ដោយផ្អែកលើការស្រាវជ្រាវបច្ចេកទេសជំនាញអភិវឌ្ឍន៍ជនបទ ។

-ធ្វើទំនាក់ទំនង សំរបសំរួល និងសហប្រតិបត្តិការជាមួយបរទេស អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នរដ្ឋ អាជ្ញាធរគ្រប់ជាន់ថ្នាក់ និងផ្នែកឯកជនដែលមានការពាក់ព័ន្ធព្រមទាំងប្រជារាស្ត្រមូលដ្ឋាន ដើម្បីធ្វើការអភិវឌ្ឍន៍ជនបទប្រកបដោយចីរភាព ។

-គ្រប់គ្រង ដឹកនាំ និងទទួលខុសត្រូវក្នុងការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍ជនបទបម្រុះថ្នាក់គ្រួសារ ភូមិ ឃុំ ដែលរួមមានផ្លូវលំជនបទ ផ្គត់ផ្គង់ទឹកជនបទ ថែទាំសុខភាពបឋម អភិវឌ្ឍន៍សហគមន៍ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

-ជំរុញការរៀបចំ និងពង្រឹងរចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទគ្រប់ជាន់ថ្នាក់ ជាពិសេសគណៈកម្មាធិការអភិវឌ្ឍន៍ជនបទនៅថ្នាក់មូលដ្ឋាន ។

## ជំពូក ៤

## អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

**មាត្រា ៦.-ថ្មី**

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ទទួលបន្ទុកធ្វើទំនាក់ទំនង សំរបសំរួល និងគ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក សម្ភារៈ បរិក្ខារ គណនេយ្យ ហិរញ្ញកិច្ច ផែនការ ស្ថិតិតាមដាន និងវាយតម្លៃសហប្រតិបត្តិការជាតិ និងអន្តរជាតិ ព្រមទាំងការងារបណ្តុះបណ្តាល ស្រាវជ្រាវ និងផ្សព្វផ្សាយ ។ អគ្គ

នាយកដ្ឋានដឹកនាំដោយអគ្គនាយកមួយរូប និងអាចអមដោយអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។ អគ្គនាយកដ្ឋាននេះមាននាយកដ្ឋានចំណុះចំនួន ៥ គឺ :

-នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក

-នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

-នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ

-នាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ

-នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច ។

**មាត្រា ១១.-ថ្មី ( បន្ថែម )**

នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិចទទួលបន្ទុក:

-រៀបចំ លើកផែនការអភិវឌ្ឍន៍សហគមន៍ជនជាតិភាគតិច សំរាប់រយៈពេលខ្លី មធ្យមនិងយូរអង្វែង ។

-សិក្សា ស្រាវជ្រាវ ពីជនជាតិភាគតិចនៅតំបន់ភ្នំ ខ្ពង់រាប និងវាលទំនាប ដោយកំណត់អោយបានច្បាស់លាស់អំពីអត្តសញ្ញាណ ប្រពៃណី វប្បធម៌ និងទំនៀមទំលាប់ដែលមានស្រាប់ក្នុងសហគមន៍នីមួយៗក្នុងព្រះរាជាណាចក្រកម្ពុជា ។

-រៀបចំ គ្រោង និងអនុវត្តកម្មវិធី និងគំរោងអភិវឌ្ឍន៍ជនជាតិភាគតិចសំរាប់តំបន់ភ្នំ ខ្ពង់រាប និងវាលទំនាប ទៅតាមលំដាប់អាទិភាពដែលបានកំណត់ ។

-សំរបសំរួល រាល់សកម្មភាពអភិវឌ្ឍន៍ជនជាតិភាគតិចនៅតំបន់ភ្នំ ខ្ពង់រាប និងវាលទំនាបក្នុងព្រះរាជាណាចក្រកម្ពុជា ។

-តាមដាន វាយតម្លៃ និងធ្វើរបាយការណ៍បូកសរុប នូវរាល់សកម្មភាពអនុវត្តកម្មវិធី និងគំរោងអភិវឌ្ឍន៍ជនជាតិភាគតិច ។

-បណ្តុះបណ្តាលដល់មន្ត្រីរាជការគ្រប់ថ្នាក់ និងរៀបចំសិក្ខាសាលា ដោយមានការចូលរួមពីគ្រប់ដៃគូអនុវត្តកម្មវិធី និងគំរោងអភិវឌ្ឍន៍ជនជាតិភាគតិច ដើម្បីជំរុញអោយមានការចូលរួមយ៉ាងសកម្មក្នុងដំណើរការអភិវឌ្ឍន៍ជនជាតិភាគតិច នៅតំបន់ភ្នំ ខ្ពង់រាប និងវាលទំនាប ។

-បង្កើត និងគ្រប់គ្រងមជ្ឈមណ្ឌលពត៌មានជាតិ ស្តីពីកិច្ចការអភិវឌ្ឍន៍តំបន់ភ្នំ និងខ្ពង់រាប ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងប្រទេសជិតខាងដែលកំពុងមានកម្មវិធីអភិវឌ្ឍន៍តំបន់ភ្នំ និងខ្ពង់រាបដូចគ្នា ។

-រៀបចំ និងកែលំអគោលនយោបាយអភិវឌ្ឍន៍ប្រជាពលរដ្ឋតំបន់ភ្នំ និងតំបន់ខ្ពង់រាប ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

-លើកឡើងនូវគោលការណ៍ណែនាំ និងកសាងលក្ខណៈវិនិច្ឆ័យ ស្តីពីការបង្កើតសហគមន៍ជនជាតិភាគតិចសំរាប់តំបន់ភ្នំ ខ្ពង់រាប និងវាលទំនាប ។

## ជំពូក ៥

## អគ្គនាយកដ្ឋានបច្ចេកទេស

### មាត្រា ១២.-ថ្មី (មាត្រា១១ចាស់ )

អគ្គនាយកដ្ឋានបច្ចេកទេសទទួលបន្ទុកធ្វើទំនាក់ទំនង សំរបសំរួល និងគ្រប់គ្រងកម្មវិធីផ្លូវលំជនបទ ផ្គត់ផ្គង់ទឹកជនបទ ថែទាំសុខភាពបឋម អភិវឌ្ឍន៍សហគមន៍ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ។ អគ្គនាយកដ្ឋាននេះដឹកនាំដោយអគ្គនាយកមួយរូប ដែលអាចអមដោយអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។ អគ្គនាយកដ្ឋានបច្ចេកទេសមាននាយកដ្ឋានចំណុះចំនួន ៥ ដូចតទៅ :

-នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ

-នាយកដ្ឋានថែទាំសុខភាពជនបទ

-នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍

-នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

-នាយកដ្ឋានផ្លូវលំជនបទ ។

### មាត្រា ១៣.-ថ្មី (មាត្រា១២ចាស់ )

នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទទទួលបន្ទុក :

-រៀបចំ លើកផែនការស្តារ និងអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពខ្នាតតូចថ្នាក់គ្រួសារ ភូមិ ឃុំ ប្រព័ន្ធថាមពលតូចៗ ព្រមទាំងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងទឹកប្រើប្រាស់សំរាប់រយៈពេលខ្លី មធ្យម និងយូរអង្វែង ។

-សិក្សា ស្រាវជ្រាវ លើកគំរោង ជួសជុល សាងសង់ និងថែទាំប្រព័ន្ធស្រោចស្រពខ្នាតតូចថ្នាក់គ្រួសារ ភូមិ ឃុំ ប្រព័ន្ធថាមពលតូចៗ ព្រមទាំងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងទឹកប្រើប្រាស់ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

-ត្រួតពិនិត្យគុណភាពទឹកអណ្តូងដែលបានជីករួច មុននឹងដាក់ជូនប្រជាពលរដ្ឋមូលដ្ឋាន ប្រើប្រាស់ ។

-រៀបចំបែបបទដែលពាក់ព័ន្ធនឹងកិច្ចដំណើរការ និងថែទាំដោយប្រជាជន នូវទឹកស្អាតទឹកប្រើប្រាស់ និងទឹកស្រោចស្រពខ្នាតតូច ព្រមទាំងការរៀបចំសមាគម ឬក្រុមអ្នកប្រើប្រាស់ទឹកនៅជនបទ ។

**មាត្រា ១៤.-ថ្មី (មាត្រា១៣ចាស់ )**

នាយកដ្ឋានថែទាំសុខភាពជនបទទទួលបន្ទុក :

-រៀបចំ លើកផែនការថែទាំសុខភាពបឋមនៅតាមសហគមន៍ជនបទ សំរាប់រយៈពេលខ្លី មធ្យម និងយូរអង្វែង ។

-បណ្តុះបណ្តាលចំណេះដឹង និងជំនាញផ្នែកថែទាំសុខភាពបឋម និងអនាម័យ ដល់មន្ត្រីរាជការអភិវឌ្ឍន៍ជនបទ និងភ្នាក់ងារសុខភាពស្ម័គ្រចិត្តតាមភូមិ ។

-អប់រំសហគមន៍អំពីការថែទាំសុខភាពបឋម ដែលជាអាទិ៍រួមមាន ការអប់រំអំពីអាហារូបត្ថម្ភ ការគាំពារសុខភាពស្ត្រី ការលូតលាស់របស់កុមារ ការថែទាំសុខភាពផ្លូវចិត្ត និងការការពារជម្ងឺផ្សេងៗ ។

-រៀបចំអនាម័យបរិស្ថានក្នុងភូមិ ដោយជួយឧបត្ថម្ភ និងបំផុសប្រជាជនចូលរួមក្នុងការសាងសង់បង្គន់អនាម័យតាមគ្រួសារ និងទីសាធារណៈ ព្រមទាំងអប់រំអ្នកភូមិអោយសំអាតលំនៅឋាន និងប្រើប្រាស់ទឹកស្អាត ។

**មាត្រា ១៥.-ថ្មី (មាត្រា១៤ចាស់ )**

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ទទួលបន្ទុក :

-រៀបចំ លើកផែនការអភិវឌ្ឍន៍សហគមន៍សំរាប់រយៈពេលខ្លី មធ្យម និងយូរអង្វែង ។

-សិក្សា ស្រាវជ្រាវ លើកគំរោង ជួសជុល និងសាងសង់សំណង់ហេដ្ឋារចនាសម្ព័ន្ធជនបទរួមមាន សាលារៀន ភូមិអភិវឌ្ឍន៍ មណ្ឌលសុខភាព ។ល។ តាមផែនការដែលបានដាក់ចុះ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

-សាងសង់ និងគ្រប់គ្រងមជ្ឈមណ្ឌលអភិឌ្ឍន៍សហគមន៍ ។

-ជំរុញ និងលើកទឹកចិត្តប្រជាជនអោយបង្កើនផលិតកម្មស្បៀងដើម្បីផ្គត់ផ្គង់គ្រួសារ និងទីផ្សារ ។

-បញ្ជូនភ្នាក់ងារអភិវឌ្ឍន៍សហគមន៍ចុះទៅតាមមូលដ្ឋានជនបទ ដើម្បីធ្វើការអប់រំក្រៅប្រព័ន្ធជូនប្រជាជនអំពីអក្ខរកម្ម ការការពារបរិស្ថាន និងធនធានធម្មជាតិ ព្រមទាំងការលើកទឹកចិត្ត

អោយដាំព្រៃឈើឡើងវិញ ការថែរក្សាប្រពៃណី វប្បធម៌ និងសីលធម៌ ក្នុងការរស់នៅ សិទ្ធិប្រជាពលរដ្ឋ លទ្ធិប្រជាធិបតេយ្យ បច្ចេកវិទ្យាសមស្របក្នុងដំណើរការផលិតកម្ម ការការពារគ្រោះថ្នាក់មីន ។ល ។

-ខិតខំជួយដោះស្រាយដល់ជនផ្លាស់ប្តូរទីលំនៅ ។

-រៀបចំបែបបទក្នុងការបង្កើត ពង្រីក និងពង្រឹងរចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទ ជាពិសេសគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ឃុំ ។

**មាត្រា ១៦.-ថ្មី (មាត្រា១៥ចាស់ )**

នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទទទួលបន្ទុក :

-រៀបចំ លើកផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទសំរាប់រយៈពេលខ្លី មធ្យម និងយូរអង្វែង ។

-រៀបចំគោលការណ៍ និងបំផុសប្រជាជនចូលរួម ក្នុងការកសាងធនាគារភូមិ ធនាគារស្រូវ ធនាគារសត្វ ធនាគារសម្ភារៈកសិកម្ម ។

-រៀបចំបែបបទ ដែលពាក់ព័ន្ធនឹងការផ្តល់ទុនជូនប្រជារាស្ត្រខ្ចី ការចងក្រងសមាគមឥណទានផ្សេងៗ ។

-លើកទឹកចិត្តប្រជារាស្ត្រជនបទអំពីការងារសន្សំប្រាក់ តាមរយៈការផ្សព្វផ្សាយ ការរៀបចំក្រុមគណៈកម្មការសន្សំប្រាក់ ការណែនាំពីវិធានការរក្សាការពារមូលនិធិសន្សំប្រាក់ ។

-គ្រប់គ្រង ណែនាំអំពីការរៀបចំបញ្ជីការគណនេយ្យសំរាប់ការងារឥណទានជនបទ ។

-ជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋ សមាគម ឬផ្នែកឯកជនផ្សេងៗ ក្នុងការសាងសង់សហគ្រាស និងសិប្បកម្មតូចតាមនៅជនបទ ។

-ស្វែងយល់ និងខិតខំរកទីផ្សារ ដើម្បីដោះស្រាយចរាចរផលិតផលដោយតម្លៃសមស្រប រួមចំណែកក្នុងការលើកស្ទួយកំរិតជីវភាពរស់នៅរបស់ប្រជាកសិករ និងសិប្បករនៅជនបទ ។

**មាត្រា ១៧.-ថ្មី (បន្ថែម)**

នាយកដ្ឋានផ្លូវលំជនបទទទួលបន្ទុក :

-រៀបចំ លើកផែនការស្តារ និងអភិវឌ្ឍន៍ផ្លូវលំជនបទសំរាប់រយៈពេលខ្លី មធ្យម និងយូរអង្វែង ។

-សិក្សា ស្រាវជ្រាវ លើកគំរោង ជួសជុល សាងសង់ និងថែទាំផ្លូវលំជនបទ ។

-តាមដាន និងវាយតម្លៃការអនុវត្តន៍កម្មវិធីការងារប្រចាំឆ្នាំ ។

-គ្រប់គ្រងផ្លូវលំជនបទទាំងអស់ដែលមានយានយន្តបើកបរតិចជាង ៥០ គ្រឿងក្នុងមួយថ្ងៃ ។

-អនុវត្ត និងវិភាគលើការរាប់ចំនួនចរាចរយានយន្ត និងការធ្វើបញ្ជីសារពើភ័ណ្ឌផ្លូវលំ ។

-រៀបចំ និងកែលំអគោលនយោបាយផ្លូវលំជនបទ ដើម្បីអោយស្របទៅតាម :

+ ជំរើសបច្ចេកវិទ្យា

+ វិធាន និងនីតិវិធីនៃកិច្ចសន្យា

+ ខ្នាតគំរូនៃបរិស្ថាន និងសុវត្ថិភាព

+ តួនាទីបុរស នារី ភាពងាយរងគ្រោះក្នុងសង្គម និងខ្នាតគំរូពលកម្ម

-រៀបចំបែបបទដែលពាក់ព័ន្ធនឹងកិច្ចដំណើរការ និងការថែទាំផ្លូវលំដោយប្រជារាស្ត្រជនបទ ដើម្បីធានាអោយមានការអភិវឌ្ឍន៍ជនបទប្រកបដោយចីរភាព ។

-បណ្តុះបណ្តាល បំពាក់បំប៉នជំនាញផ្លូវលំ ដល់មន្ត្រីរាជការដែលទទួលខុសត្រូវក្នុងការអនុវត្តន៍ និងត្រួតពិនិត្យលើការអនុវត្តន៍កម្មវិធី និងគំរោងផ្លូវលំ ។

## ជំពូក ៦

## ខុទ្ទកាល័យរដ្ឋមន្ត្រី

### មាត្រា ១៨.-ថ្មី (មាត្រា១៦ចាស់ )

ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូក ៧

## អង្គភាពមូលដ្ឋាន

### មាត្រា ១៩.-ថ្មី (មាត្រា១៧ចាស់ )

នៅតាមខេត្ត / ក្រុងនីមួយៗ មានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត / ក្រុងមួយ ដែលទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ______

## ជំពូក ៨

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ២០.-ថ្មី (មាត្រា១៨ចាស់ )**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ជាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

## ជំពូក ៩

## អវសានបញ្ញត្តិ

**មាត្រា ២១.-ថ្មី (មាត្រា១៩ចាស់ )**

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង នៅរដ្ឋបាលកណ្តាលចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។

**មាត្រា ២២.-ថ្មី (មាត្រា២០ចាស់ )**

ភារកិច្ចទាំងឡាយណា ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ស្ថាប័នដទៃ ប្រធានស្ថាប័ននៃស្ថាប័នដទៃទាំងនោះ និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវសហការគ្នាដើម្បីបែងចែកការងារទទួលខុសត្រូវ និងអនុវត្តការងារទាំងនោះតាមរយៈប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងប្រធានស្ថាប័នទាំងនោះ ។

**មាត្រា ២៣.-ថ្មី (មាត្រា២១ចាស់ )**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៤.-ថ្មី (មាត្រា២២ចាស់ )**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ និងអភិបាលគ្រប់ខេត្ត ក្រុងមានភារកិច្ចអនុវត្ត

អនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

ហត្ថលេខា និងត្រា

**ឈឹម សៀកឡេង**

===

# អង្គការលេខរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ:
ចុះថ្ងៃទី ខែ ឆ្នាំ២០០១



# អនុក្រឹត្យលេខ ៥២ អនក្រ.បក
# ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

-បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១** .- ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ១.៤៥០ លានរៀល ( មួយពាន់បួនរយហាសិបលានរៀល ) ពីជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) មក

ជំពូក ១០ ( បៀវត្ស និងប្រាក់បំណាច់ ) របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា ២ .-** ឥណទានថវិកា ក្នុងមាត្រា ១ ខាងលើ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់ទូទាត់ប្រាក់ឧបត្ថម្ភជាបណ្តោះអាសន្នដល់មន្ត្រីបច្ចេកទេសនៃមាត់ច្រកទូរគមនាគមន៍អន្តរជាតិ (International Gateway ) ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

រដ្ឋមន្ត្រីស្តីទី

ហត្ថលេខា និងត្រា

**អ៊ុក រ៉ាប៊ុន**

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

===

## អនុក្រឹត្យលេខ ៥៣ អនក្រ.បក

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

-បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១ .-** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានចរិកាសរុបចំនួន ២៥.៦៣០ លានរៀល ( ម្ភៃប្រាំពាន់ប្រាំមួយរយសាមសិបលានរៀល ) ពីជំពូក ៤០ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) ចំនួន ៣.៦៣០ លានរៀល (បីពាន់ប្រាំមួយរយសាមសិបលានរៀល ) និងជំពូក ៤០ (ចំណាយផ្សេងៗ) ចំនួន ២២.០០០ លានរៀល ( ម្ភៃពីរពាន់លានរៀល ) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ការ គ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា ២ .-** ឥណទានថវិកា ក្នុងមាត្រា ១ ខាងលើ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់ចំណាយដំណើរការរដ្ឋបាលសំភារៈ និងការជួសជុលតូច និង ទូទាត់ចំណាយបង្វិលសងប្រាក់អាករលើតំលៃបន្ថែម ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា និងត្រា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

===

## អនុក្រឹត្យលេខ ២៥២ អនក្រ.តត

## ស្តីពីការជូនមេដាយ ការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**សំរេច**

**មាត្រា ១ ._** ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូននាយនគរបាល និងមន្ត្រីរាជការ ចំនួន ៤៤ រូប នៃក្រសួងមហាផ្ទៃ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច ត្រួតពិនិត្យចុះបញ្ជី និងបើកផ្តល់ប្រាក់ឧបត្ថម្ភផ្ទាល់ជូនកងជីវពលដូចមានរាយនាមខាងក្រោមនេះ :

**ក_មេដាយប្រាក់ការងារ :**

១-លោកវរសេនីយ៍ឯក **យន់ សន** អនុប្រធានទី១ នាយកដ្ឋានផែនការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២-លោកវរសេនីយ៍ឯក **ខា គីមលី** អនុប្រធានសេនាធិការដ្ឋាននៃអគ្គនាយកដ្ឋាននគរបាលជាតិ

៣-លោកវរសេនីយ៍ឯក **ព្រុំ ឆាន** អនុប្រធានធិការដ្ឋានកិច្ចការនគរបាល

៤-លោកវរសេនីយ៍ឯក **រស់ នឹមសារុន** អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៥-លោកស្រីវរសេនីយ៍ឯក **អ៊ុន សុគន្ធា** អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៦-លោកវរសេនីយ៍ឯក **តឹក សំអ៊ុក** អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៧-លោកវរសេនីយ៍ឯក **មុំ ព្រិច** អនុប្រធានអធិការដ្ឋានកិច្ចការនគរបាល

**ខ_មេដាយសំរិទ្ធការងារ :**

១-លោកវរសេនីយ៍ទោ **ឌឹម ណារិទ្ធ** នាយការិយាល័យផែនការ នាយកដ្ឋានផែនការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២-លោកវរសេនីយ៍ទោ **ឆេស ថាន់នី** នាយការិយាល័យគណនេយ្យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៣-លោកវរសេនីយ៍ទោ **សៀង សុខ** នាយការិយាល័យត្រួតពិនិត្យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៤-លោកវរសេនីយ៍ត្រី **ស៊ុន រ៉ូ** នាយរងការិយាល័យផែនការ នាយកដ្ឋានផែនការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៥-លោកវរសេនីយ៍ត្រី **អៀម បូណារ័ត្ន** នាយរងការិយាល័យផែនការ បណ្តុះបណ្តាល នាយកដ្ឋានបុគ្គលិក

៦-លោកវរសេនីយ៍ត្រី **ជុំ សុខា** នាយរងការិយាល័យត្រួតពិនិត្យ នាយកដ្ឋានផែនការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៧-លោកវរសេនីយ៍ត្រី **សុខ សារ៉េត** នាយរងការិយាល័យហិរញ្ញកិច្ច នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៨-លោកវរសេនីយ៍ត្រី **ម៉ៅ ទាំងដា** នាយរងការិយាល័យបៀវត្សរ៍ នាយកដ្ឋានបុគ្គលិក

៩-លោកវរសេនីយ៍ត្រី **ខៀវ តារារដ្ឋ** ជំនួយការឯកឧត្តមប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១០-លោកវរសេនីយ៍ត្រី **កើត សំផន** នាយរងការិយាល័យគោលនយោបាយ នាយកដ្ឋានបុគ្គលិក

១១-លោកវរសេនីយ៍ត្រី **ប៊ី ឈុងហ៊ុ** នាយរងការិយាល័យគណនេយ្យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១២-លោកវរសេនីយ៍ត្រី **អៀង ច័ន្ទសុផល** នាយរងការិយាល័យរដ្ឋបាល សរុប នាយកដ្ឋាន បុគ្គលិក

១៣-លោកវរសេនីយ៍ត្រី **គុប សំណាង** នាយរងការិយាល័យរដ្ឋបាល សរុប នាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១៤-លោកវរសេនីយ៍ត្រី **អ៊ុយ សារ៉ន** នាយរងការិយាល័យគណនេយ្យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១៥-លោកវរសេនីយ៍ត្រី **ថូ សាខា** នាយរងការិយាល័យគោលនយោបាយ នាយកដ្ឋានបុគ្គលិក

១៦-លោកវរសេនីយ៍ត្រី **អ៊ុក សុខុម** នាយរងការិយាល័យរដ្ឋបាល សរុប នាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១៧-លោកវរសេនីយ៍ត្រី **ញ៉ឹក សុផល** នាយរងការិយាល័យបណ្តុះបណ្តាល នាយកដ្ឋានបុគ្គលិក

១៨-លោកវរសេនីយ៍ត្រី **ណារុល ផារិទ្ធិ** នាយរងការិយាល័យផែនការ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១៩-លោកអនុសេនីយ៍ឯក **គឹម ម៉េងហេង** នាយផ្នែកការិយាល័យផែនការ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២០-លោកអនុសេនីយ៍ឯក **សែន វឌ្ឍនា** នាយផ្នែកការិយាល័យត្រួតពិនិត្យនាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២១-លោកអនុសេនីយ៍ឯក **គឹមសុខ សុផល** នាយផ្នែកការិយាល័យត្រួតពិនិត្យនាយកដ្ឋាន ផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២២-លោកអនុសេនីយ៍ឯក **មូល សារឿន** នាយផ្នែកការិយាល័យរដ្ឋបាល សរុប នាយកដ្ឋាន ផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២៣-លោកអនុសេនីយ៍ទោ **មិន សុខុន** នាយរងផ្នែកការិយាល័យត្រួតពិនិត្យនាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២៤-លោកអនុសេនីយ៍ទោ **សយ សារុន** នាយរងផ្នែកការិយាល័យហិរញ្ញកិច្ច នាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២៥-លោកអនុសេនីយ៍ទោ **កន សំអាត** នាយរងផ្នែកការិយាល័យត្រួតពិនិត្យនាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២៦-លោកអនុសេនីយ៍ទោ **ឈ សារ៉េត** នាយរងផ្នែកការិយាល័យរដ្ឋបាល សរុប នាយកដ្ឋាន ផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២៧-លោកអនុសេនីយ៍ទោ **ជុំ រឹម** នាយរងផ្នែកការិយាល័យរដ្ឋបាល សរុប នាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២៨-លោកអនុសេនីយ៍ទោ **នួច រ៉ាមី** នាយរងផ្នែកការិយាល័យគណនេយ្យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២៩-លោក **ក្លយ ចាន់ថុល** មន្ត្រី នាយកដ្ឋានបុគ្គលិក

៣០-លោក **នង សារិន** មន្ត្រី នាយកដ្ឋានបុគ្គលិក

៣១-លោក **សរ ជេដ្ឋា** មន្ត្រី នាយកដ្ឋានបុគ្គលិក

៣២-លោក **គង់ សម្បត្តិ** មន្ត្រី នាយកដ្ឋានបុគ្គលិក

៣៣-លោក **ចាន់ សុខេង** មន្ត្រី នាយកដ្ឋានបុគ្គលិក

៣៤-លោក **ខួន នី** មន្ត្រី នាយកដ្ឋានបុគ្គលិក

៣៥-លោក **ស្មោច សុខា** មន្ត្រី នាយកដ្ឋានបុគ្គលិក

៣៦-លោក **ជា សុផាត** មន្ត្រី នាយកដ្ឋានបុគ្គលិក

៣៧-លោក **យឹម សម្បត្តិ** មន្ត្រី នាយកដ្ឋានបុគ្គលិក

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ២៤៣ អនក្រ.តត

## ស្តីពីការដំឡើងឋានៈមន្ត្រី

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

**សំរេច**

**មាត្រា ១ .-** ត្រូវបានបំពាក់ មេដាយសហមេត្រី តាមលំដាប់ថ្នាក់ជូនមន្ត្រីយោធាបារាំងចំនួន ០៥ រូប ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការលើកស្ទួយនូវចំណងមិត្តភាព និង កិច្ចសហប្រតិបត្តិការរវាងកងទ័ពសាធារណរដ្ឋបារាំង និង កងយោធពលខេមរភូមិន្ទ ដូចមានរាយនាមខាងក្រោមនេះ :

**ក-មេដាយសហមេត្រី** ថ្នាក់ " **សេនា** " :

-លោកវរសេនីយ៍ឯក **ប៊ែរណាដ៏ ហ្វេសស្កេត៍** ( Colonel Bernard FESQUET )

**ខ-មេដាយសហមេត្រី** ថ្នាក់ " **អស្សឫទ្ធិ** " :

១-លោកវរសេនីយ៍ត្រី **ហ្សាក់ អាស្តាកូហ្វ** ( CBA Jacques ASTAKOF )

២-លោកអនុសេនីយឯក **ប៊ែនហ្សាម៉ង ហ្គីយ៉ូម** (Capitaine Benjamin GUILLAUME )

៣-លោកអនុសេនីយឯក **ប៉ាស្កាល់ អ៊ីយ៉ានី** (Capitaine Pascal IANNI )

៤-លោកព្រឹន្ទបាលទោ **អាឡាំង មីហ្គ្លីយោរីនី** ( Adjudant Alain MIGLIORINI )

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវ អនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

===

## អនុក្រឹត្យលេខ ២៥៤ អនក្រ.តត
## ស្តីពីការជូនមេដាយសុវត្ថារា

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

**សំរេច**

**មាត្រា ១ .-** ត្រូវបានបំពាក់ **មេដាយសុទន្តារា** ថ្នាក់ " **ធិបឌិន្ទ** " ជូនលោកឧកញ៉ា **អ៊ឹង ម៉ុនហ៊ុង** ដែល បានចូលរួមវិភាគទាន ជាថវិកា សំភារៈ និងស្បៀងអាហារ រួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការជួយសង្គ្រោះប្រជាពលរដ្ឋ និងកសាងប្រទេសជាតិ ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

---

## អនុក្រឹត្យលេខ ២៥៥ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

**សំរេច**

**មាត្រា ១.-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ០៣ រូប ដែលបានបរិច្ចាគនូវបច្ច័យ និង ថវិកា ដើម្បីជួយកសាងព្រះវិហារពីរជាន់ និង កសាងសមិទ្ធផល នានាជាច្រើនទៀត ក្នុងវិស័យព្រះពុទ្ធសាសនា ស្ថិតនៅក្នុងវត្តសីសៈទីបៈមូលីយារ៉ាម ឃុំ កោះ ឧកញ៉ាតី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ :

១-ព្រះតេជគុណ **ឆា នៅ** ព្រះចៅអធិការវត្តសីសៈទីបៈមូលីយារ៉ាមបច្ច័យចំនួន ២៤.៣៨៥ ដុល្លារអាមេរិក

២-លោកឧត្តមសេនីយ៍ត្រី **សែម សុវណ្ណនី** មេបញ្ជាការរង នៃបញ្ជាការដ្ឋានវិស្វកម្ម ថវិកា ចំនួន ១៤២.៧៨៤ ដុល្លារអាមេរិក

៣-លោកស្រី **ចាន់ សុធ្ធា** នាយកក្រុមហ៊ុន CREDIT Co.LTD ថវិកាចំនួន ១៣១.២១១ ដុល្លារអាមេរិក

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

===

## អនុក្រឹត្យលេខ ២៥៦ អនក្រ.តត
## ស្តីពីការជូនមេដាយសុវត្ថារា

~

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

**សំរេច**

**មាត្រា ១** .- ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ "**ធិបឌិន្ទ**" ជូនលោកឧកញ៉ា **គិត ម៉េង** ដែលបានចូលរួមវិភាគទាន ជាថវិកា សំភារៈ និងស្បៀងអាហារ រួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការជួយសង្គ្រោះប្រជាពលរដ្ឋ និងកសាងប្រទេសជាតិ ។

**មាត្រា ២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

===

# អនុក្រឹត្យលេខ ២៥៧ អនក្រ.តត

# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

**សំរេច**

**មាត្រា ១.-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះតេជគុណសារទត្ថោ **កែវ ម៉ៅ ចំរើន** ដែលមានព្រះទ័យជ្រះថ្លា ក្នុងវិស័យព្រះពុទ្ធសាសនា បានជួយកសាង ព្រះវិហារ កុដិ ក្លោងទ្វារវត្ត និងកសាងសមិទ្ធផលជាច្រើន នៅក្នុងវត្តឧត្តរាវតី សង្កាត់ឫស្សីកែវ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រមទាំងវត្តដទៃជាច្រើនទៀត សរុបជាបច្ច័យចំនួន ១០១.០៦៥ USD និង ១០.០០០.០០០ រៀល ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

===

**អនុក្រឹត្យលេខ ២៥៨ អនក្រ.តត**

**ស្តីពីការជូនមេដាយសមាមេត្រី**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គលេខាធិការព្រឹទ្ធសភា

**សំរេច**

**មាត្រា ១** .- ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនឯកឧត្តមឯកអគ្គរដ្ឋទូត សហការី និង អ្នកជំនាញការបច្ចេកទេស នៃសាធារណរដ្ឋប្រជាមានិតចិន ដែលបានជួយខ្នះខ្នែងអន្តរាគមន៍សុំជំនួយពីរដ្ឋាភិបាល និង រដ្ឋសភា នៃសាធារណរដ្ឋប្រជាមានិតចិន យកមកសាងសង់ សាលប្រជុំព្រឹទ្ធសភា ជួសជុលដំបូល អាគារក្រហម កសាងអាគារការិយាល័យសមាជិកព្រឹទ្ធសភា ០៣ ខ្នង បណ្ណាល័យ ០១ ខ្នង និងសមិទ្ធផលមួយចំនួនទៀតមានតំលៃជាទឹកប្រាក់ជិត ៣ លានដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ :

**ក.មេដាយសហមេត្រី ថ្នាក់ " ធិបឌិន្ទ "**

-ឯកឧត្តម Ning Fukui ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពនៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា

**ខ.មេដាយសហមេត្រី ថ្នាក់ " សេនា "**

១-លោក Peng Gang ទីប្រឹក្សាទទួលបន្ទុកសេដ្ឋកិច្ច និង ពាណិជ្ជកម្មអមស្ថានទូត

២-លោក Wang Xuelin លេខាទី១ នៃស្ថានទូតនិងជាអ្នកទទួលបន្ទុកគំរោងសាងសង់

៣-លោក Liu Hongbin នាយក នៃក្រុមហ៊ុនសំណង់មហាកំពែង

៤-លោក Zhou Yongjian នាយករង នៃក្រុមហ៊ុនសំណង់មហាកំពែង

**មាត្រា ២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង អគ្គលេខាធិការព្រឹទ្ធសភា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ២៥៩ អនក្រ.តត
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តបាត់ដំបង

## សំរេច

**មាត្រា ១ .-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ម៉ុី វ៉េន** តំណាងសប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន និង លះបង់ពេលវេលាក្នុងការខិតខំរកថវិកាជួយកសាងអាគារសិក្សា ០១ ខ្នង ធ្វើពីថ្មមាន ០៣ បន្ទប់ និង សមិទ្ធផលមួយចំនួនទៀតព្រមទាំងតុកៅអី សិស្ស គ្រូ គ្រប់ចំនួន នៅសាលាបឋមសិក្សា កងកេងភូមិថ្មី ឃុំកំពង់ព្រៀង ស្រុកសង្កែ ខេត្តបាត់ដំបង ចំណាយអស់ទឹកប្រាក់ចំនួន ២០.៨៥៣.៦៤ ដុល្លារអាមេរិក ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

## អនុក្រឹត្យលេខ ២៦០ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តបាត់ដំបង

## សំរេច

**មាត្រា ១ .-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូននាយករងវិទ្យាស្ថានជាតិគ្រប់គ្រងចំនួន ០២ រូប ដែលបានរួមចំណែកជាមួយ ឯកឧត្តម អ៊ីវ ថុង ជួយស្ថារ និង អភិវឌ្ឍនីវិស័យអប់រំបណ្តុះបណ្តាលធនធានមនុស្ស នៅក្នុងខេត្តបាត់ដំបង ដោយបានរំលែកថវិកាចំនួន ៥០០.០០០ ដុល្លារអាមេរិក ពីវិទ្យាស្ថានជាតិគ្រប់គ្រងភ្នំពេញ យកទៅជួសជុលស្តារឡើងវិញ វិទ្យាស្ថានជាតិគ្រប់គ្រងសាខា ខេត្តបាត់ដំបង " អតីតសាលាសកល " ដូចមានរាយនាមខាងក្រោមនេះ :

១-លោកបណ្ឌិត **ឡោ សុជាតិ**

២-លោក **អ៊ុំ សុគន្ធ**

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

**អនុក្រឹត្យលេខ ២៦១ អនក្រ.តត**

**ស្តីពីការជូនមេដាយសុវត្ថារា**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា ១**.- ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ "**ធិបឌិន្ទ**" ជូនឯកឧត្តម **ម៉ែន ស៊ីម៉ន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និង រដ្ឋាករ ដែលមានស្នាដៃឆ្នើម ក្នុងការដឹកនាំ និងគ្រប់គ្រងអង្គភាព អនុវត្តចំណូលថវិការដ្ឋបានលើសផែនការក្នុងឆ្នាំ ១៩៩៩ ព្រមទាំងមានយុទ្ធវិធី ក្នុងការពូតផ្តុំធនធានមនុស្ស និង មានគំនិតសាងសង់បានអាគារថ្មីបីជាន់សំរាប់អង្គភាព ។

**មាត្រា ២**.- ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

===

# អនុក្រឹត្យលេខ ២៦២ អនក្រ.តត
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១ .-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០២ រូបដែលបានបរិច្ចាគថវិកា ផ្ទាល់ខ្លួន ដើម្បីជួយកសាងសាលារៀនខ្មែរ ចិន មេច ម៉េច និងវិទ្យាល័យស្រុកភ្នំពេញ ចំនួន ០១ ខ្នង មាន ១៣ បន្ទប់ ធ្វើអំពីបេតុង ប្រក់ហ្វីប្រូស៊ីម៉ង់ត៍ ស្ថិតនៅក្នុងខេត្តកណ្តាល ដូចមានរាយ នាមខាងក្រោម :

១-ឯកឧត្តម ផៃ **ម៉ិនឈឿន** ទីប្រឹក្សាផ្ទាល់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភាជាតិ ថវិកា ចំនួន ២០.000 USD

២-លោក **យូ គីមឡេង** នាយកក្រុមហ៊ុនឆ្នោតមហាសម្បត្តិ ថវិកាចំនួន ២០.000 USD

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ២៦៣ អនក្រ.តត
# ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១ .-** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ " **ធិបឌិន្ទ** " ប្រគេនព្រះតេជគុណ **សួន យឿន** ចៅអធិការវត្តអង្គត្រគៀត ព្រះអង្គបានយកអស់កម្លាំងកាយពល និង ធំណាករ នូវបច្ច័យយ៉ាងច្រើនសន្ធឹកសន្ធាប់ ចាប់តាំងពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ២០០១ ដើម្បីកសាងសមិទ្ធផលនានាជាច្រើន សរុបបច្ច័យចំនួន ៥៨៨.៦៧៤ ដុល្លារអាមេរិក ស្ថិតនៅក្នុងវត្តអង្គត្រគៀក ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្ត កណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

===

# អនុក្រឹត្យលេខ ២៦៤ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តព្រៃវែង

## សម្រេច

**មាត្រា ១ .-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម ០២ រូប ដែលបានចំណាយនូវថវិកា ដើម្បីជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា និង វិស័យអប់រំ ស្ថិតក្នុងស្រុកកំចាយមារ ខេត្ត ព្រៃវែង ដូចមានរាយនាមខាងក្រោមនេះ :

១-ឯកឧត្តម **ឡូយ សុផាត** អភិបាលខេត្តក្រចេះ ជួយកសាងសាលាអនុវិទ្យាល័យ និងសាលាបឋមសិក្សាជាថ ០៣ ខ្នង មាន ១៥ បន្ទប់ថវិកាសរុបចំនួន ៧៨.០០០.០០០ រៀល

២-ឯកឧត្តម **ដោក ណារិន** អនុរដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា ជួយកសាងព្រះវិហារ និង សាលារៀន ០២ ខ្នង ០៨បន្ទប់

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ________

**អនុក្រឹត្យលេខ ២៦៥ អនក្រ.តត**

**ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ**

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ .-** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម :

១-លោកស្រីវរនីយ៍ទោ **អ៊ុម ខូ** អនុប្រធានការិយាល័យសរុបស្ថិតិ នៃខុទ្ទកាល័យ

២-លោកវរសេនីយ៍ទោ **នូច ណារ៉ុថ** ស្នងការ នៃស្នងការដ្ឋាន នគរបាលខេត្តកំពង់ឆ្នាំង

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

# **អនុក្រឹត្យលេខ ២៦៦ អនក្រ.គត**

## **ស្តីពីការជូនមេដាយស្ថាបនាជាតិ**

## **រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

## **សំរេច**

**មាត្រា ១ .-** ត្រូវបានរំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការអន្តរជាតិស្ម័គ្រចិត្តប្រទេសជប៉ុន ហ្សឺ រ៉េ សេ ដែលបានជួយកសាងអាគារសិក្សា ០១ខ្នង មាន ០៣ បន្ទប់ ធ្វើអំពីបេតុងប្រក់ក្បឿង សរុបទឹកប្រាក់ ១៨.០០០ ដុល្លារអាមេរិក ស្ថិតនៅក្នុងសាលាបឋមសិក្សាឧបសម្ព័ន្ធជង្រុក ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

===

## អនុក្រឹត្យលេខ ២៦៧ អនក្រ.តត
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១ .-** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ "**ធិបឌិន្ទ**" ប្រគេនព្រះតេជគុណ វេទិវង្សា **ខា សំអាន** ព្រះបាឡាត់គណខេត្តកណ្តាល និង ជាព្រះចៅអធិការវត្តសុវណ្ណវារី ឃុំព្រែកតាទែន ដែលបានបរិច្ចាគនូវបច្ច័យ ដើម្បីជួយកសាងសមិទ្ធផលនានាជាច្រើនក្នុងវិស័យព្រះពុទ្ធសាសនា វិស័យអប់រំសិក្សា និង វិស័យសង្គមកិច្ច សរុបបច្ច័យចំនួន ២២៧.២៧២ ដុល្លារអាមេរិក ស្ថិតនៅក្នុង ស្រុកពញាឮ ខេត្តកណ្តាល ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្ត កណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ២៦៨ អនក្រ.តត
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១ .-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកគ្រូមហាចក្រ **ម៉ៅ រិទ្ធិថា** គង់នៅចេតិយទន្លីមភ្នំអង្គរស្ស ឃុំផ្សារដែក ដែលបានចំណាយថវិកាដើម្បីជួយកសាងសមិទ្ធផលនានា ដូចជាកសាងកុដិធ្វើផ្លូវចាក់គ្រួសក្រហម ជណ្តើរឡើងភ្នំ និង ចែកអំណោយជូនប្រជាជនក្នុងរយៈពេល ០៤ ឆ្នាំ កន្លងមកសរុបទឹកប្រាក់ចំនួន ៤៦.៥០០ ដុល្លារអាមេរិក និង ២០.៨០០.០០០រៀល ស្ថិតនៅក្នុងស្រុកពញាឮ ខេត្តកណ្តាល ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្ត កណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយចចូលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

===

**អនុក្រឹត្យលេខ ២៦៩ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

**សំរេច**

**មាត្រា ១ .-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០៤ រូប ដែលបានចំណាយថវិកាដើម្បីជួយកសាងសមិទ្ធផលនានាជាច្រើនក្នុងវិស័យព្រះពុទ្ធសាសនា និង វិស័យអប់រំស្ថិតនៅក្នុងវត្តធម្មស្រះ ឃុំភ្នំបាត ស្រុកពញាឮ ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម **នុត សុខុម** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ថវិកាចំនួន ៨៦.០៧០ ដុល្លារអាមេរិក

២-លោក **ខេត សុចាត** មន្ត្រីបំរើការនៅមន្ទីរពេទ្យកុមារជាតិ ថវិកាចំនួន ២៨.៥០០ ដុល្លារអាមេរិក

៣-លោក **សៀវ តេកអ៊ីង** អាជីវករនៅរាជធានីភ្នំពេញ ថវិកាចំនួន ២៣.២០០ ដុល្លារអាមេរិក

៤-លោកវរសេនីយ៍ត្រី **ខៀវ វីរៈ** ថវិកា ចំនួន ១៨.០០០ ដុល្លារអាមេរិក

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្ត កណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

====

## ២_ សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០១

**សេចក្តីសំរេចលេខ ៣៣ សសរ**

**ស្តីពីការធ្វើវិសោធនកម្មលើសេចក្តីសំរេចលេខ ០៧ សសរ**

**ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០១**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគនៃ ព្រះរាជាណាចក្រកម្ពុជា

-យោងអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យកែតំរូវលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩

-យោងអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩

-យោងសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ០៧ សសរ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមការងារតាមវិស័យ សំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន

-យោងសេចក្តីជូនដំណឹងលេខ ១៩៩ សជណ.សរ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីលទ្ធផលនៃវេទិការាជរដ្ឋាភិបាល វិស័យឯក ជនលើកទី៣ នាថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០១

**សំរេច**

**ប្រការ ១** : បង្កើតក្រុមការងារផ្នែកសេវាកម្មធនាគារ និងហិរញ្ញវត្ថុ ជំនួសអោយក្រុមការងារផ្នែកសេវាកម្ម រាប់បញ្ចូលទាំងសេវាធនាគារ និងហិរញ្ញវត្ថុ ដែលមានចែងក្នុងសេចក្តីសំរេចលេខ ០៧ សសរ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០១ ។

**ប្រការ ២** : ក្រុមការងារផ្នែកសេវាកម្មធនាគារ និងហិរញ្ញវត្ថុនេះ មានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ជា ចាន់តូ** ទេសាភិបាល ធនាគារជាតិ នៃកម្ពុជា ប្រធាន

២-ឯកឧត្តម **វង្ស វ៉ាថ្មី** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៣-ឯកឧត្តម **សុន គន្ធរ** ប្រធានអគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ សមាជិក

៤-ឯកឧត្តម **ឯម សំអាន** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ សមាជិក

៥-ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៦-ឯកឧត្តម**សុខ្ខ សុធន្ន** អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ សមាជិក

៧-ឯកឧត្តម **សយ សុខា** អគ្គលេខាធិការក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សមាជិក

**ប្រការ ៣** : បន្ថែមភារកិច្ចក្នុងចំណុច " ឃ " ប្រការ ១ នៃសេចក្តីសំរេចលេខ ០៧ សសរ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១ នូវឃ្លីមសារសហគ្រាសធុនតូច មធ្យម ដោយអានថា : ឃ- ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារអភិបាលកិច្ច នឹងសហគ្រាសធុនតូច - មធ្យម ។

**ប្រការ ៤** : ក្រុមការងារផ្នែកសេវា រាប់បញ្ចូលទាំងសេវាធនាគារ និងហិរញ្ញវត្ថុ ត្រង់ចំណុច " ង " ដែលមានចែងក្នុងសេចក្តីសំរេចលេខ ០៧ សសរ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១ ត្រូវចាត់ទុកជានិរាករណ៍ ។

ក្រៅពីនេះ ខ្លឹមសារដែលមានចែងក្នុងសេចក្តីសំរេចលេខ ០៧ សសរ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១ នៅរក្សាទុកជាធរមានដដែល ។

**ប្រការ ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិល អាជ្ញាធរអប្សរា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

===

រាជធានីភ្នំពេញ . ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០១

**សេចក្តីសំរេចលេខ ៣៤ សសរ**

**ស្តីពីការបង្កើតក្រុមការងារដើម្បីសិក្សាលើការរៀបចំកសាង**

**កំពង់ផែទេសចរណ៍នៅខេត្តសៀមរាប**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ០១/នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប អង្គរ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិដើម្បីការពារមណ្ឌលនិងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរ " អប្សរា "

-តាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :**

បង្កើតក្រុមការងារ ដើម្បីសិក្សាលើការកសាងរៀបចំកំពង់ផែទេសចរណ៍នៅខេត្តសៀមរាប ដែលមានសមាសភាពដូចខាងក្រោមនេះ :

១-ឯកឧត្តម **ព្រហ្ម សិទ្ធត្រា** អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ប្រធាន

២-ឯកឧត្តម **អ៊ុក សូមេត្ត** អគ្គនាយករងអាជ្ញាធរអប្សរា អនុប្រធាន

៣-ឯកឧត្តម **តែប ថន** អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន អនុប្រធាន

៤-ឯកឧត្តម **ឌុច ច័ន្ទនិត្យ** អគ្គនាយករៀបចំដែនដី និងនគរូបនីយកម្ម សមាជិកអចិន្ត្រៃយ៍

៥-លោក **ស៊ុយ សាន** អភិបាលរងខេត្តសៀមរាប សមាជិក

៦-លោក **លឹម វាន់** អគ្គនាយករងសុរិយោដី និងភូមិសាស្ត្រ សមាជិក

៧-លោក **នុត សាខន** ប្រធាននាយកដ្ឋាន កៀត្រសាស្ត្រ និងកែលំអដី នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៨-លោក **ឯម ម៉ុនធឿន** ប្រធាននាយកដ្ឋានទឹកស្អាត នៃក្រសួងធនធានទឹក និងឧតុនិយម សមាជិក

៩-លោក **ទេស សំអឿ** ប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ នៃក្រសួងទេសចរណ៍ សមាជិក

១០-លោក **ឌួន គង់** អនុប្រធាននាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន នៃក្រសួងបរិស្ថាន សមាជិក

១១-លោក **អ៊ុយ គីមឈាង** អនុប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

**ប្រការ ២ :**

ក្រុមការងារនេះ មានភារកិច្ចដូចតទៅ :

-សិក្សាស្រាវជ្រាវលើទិដ្ឋភាពបច្ចេកទេស ដើម្បីកសាង ឬរៀបចំគំរោងអភិវឌ្ឍន៍កំពង់ផែទេសចរណ៍ខេត្តសៀមរាប និងហេដ្ឋារចនាសម្ព័ន្ធ ដែលពាក់ព័ន្ធ

-សិក្សាស្រាវជ្រាវលើការជីកប្រឡាយបង្ហូរទឹក សំរាប់ចំរើនលើលផលប្រយោជន៍កសិកម្ម ដោយសិក្សាលំអិត ស្តីពីហេតុផលប៉ះពាល់បរិស្ថានផងដែរ

-បង្កលក្ខណៈអនុគ្រោះអោយក្រុមហ៊ុន HOWA -CRAFT អាចធ្វើអាជីវកម្មបានរវាងភ្នំពេញ និងសៀមរាប

-លើកយោបល់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេចលើគំរោងកសាងកំពង់ផែ និងហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធទាំងអស់ ។

**ប្រការ ៣ :**

ក្រុមការងារអភិវឌ្ឍន៍តំបន់កំពង់ផែទេសចរណ៍ខេត្តសៀមរាបនេះ ត្រូវមានលេខាធិការដ្ឋានមួយសំរាប់ដំណើរការរៀបចំការងារ ដែលមានស្នាក់ការនៅក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង

សំណង់ ស្ថិតក្រោមការដឹកនាំរបស់ឯកឧត្តម ឌុច វនទិត្យ ហើយមាន សិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ក្រុមការងារនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ហើយមានសិទ្ធិអញ្ជើញអ្នកបច្ចេកទេសចូលរួមតាមការចាំបាច់ និងត្រូវរាយការណ៍ ជូនរាជរដ្ឋាភិបាលលើលទ្ធផលនៃការងាររបស់ខ្លួន ។

**ប្រការ ៤ :**

ក្រុមការងារនេះត្រូវ រំសាយជាស្វ័យប្រវត្តិ នៅពេលដែលបានបំពេញភារកិច្ចចប់ជាស្ថាពរ ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អភិបាលខេត្តសៀមរាប និងគ្រប់សមាសភាពដែលមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

## សេចក្តីសំរេចលេខ ៣៥ សសរ

## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំញៀន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ ការប្រព្រឹត្តិទៅ របស់ក្រសួងសុខាភិបាល

-បានទទួល ការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០០១

**សំរេច**

**ប្រការ ១** : បង្កើតគណៈកម្មការអន្តរក្រសួង ដែលមានឈ្មោះ " គណៈកម្មការអន្តរក្រសួងដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ " ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-រដ្ឋមន្ត្រីក្រសួងសុខាភិបាល | | ប្រធាន |
| ២-រដ្ឋលេខាធិការក្រសួងសុខាភិបាល | | អនុប្រធានអចិន្ត្រៃយ៍ |
| ៣-អនុរដ្ឋលេខាធិការក្រសួងពត៌មាន | | អនុប្រធាន |
| ៤-អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១ រូប | សមាជិក |
| ៥-អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងពាណិជ្ជកម្ម | ០១ រូប | សមាជិក |
| ៦-អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ០១ រូប | សមាជិក |
| ៧-អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១ រូប | សមាជិក |
| ៨-អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងបរិស្ថាន | ០១ រូប | សមាជិក |
| ៩-អគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំង នឹងគ្រឿងញៀន | ០១ រូប | សមាជិក |
| ១០-នាយកខុទ្ទកាល័យក្រសួងមហាផ្ទៃ | ០១ រូប | សមាជិក |
| ១១-ប្រធានមជ្ឈមណ្ឌលជាតិ លើកកំពស់សុខភាព | | សមាជិក និងជាលេខាធិការ |

**ប្រការ ២ :**

គណៈកម្មការអន្តរក្រសួងមានតួនាទី និងភារកិច្ចដូចតទៅ :

១-សំរបសំរួលលើការអង្កេតនិងសិក្សាស្រាវជ្រាវជាអាទិភាព មានជាអាទិ៍ ការអង្កេតលើការប្រើប្រាស់ថ្នាំជក់ និងផលវិបាកនៃការប្រើប្រាស់ថ្នាំជក់ លើសុខភាព និងសេដ្ឋកិច្ច

២-តាមដាន និងវាយតម្លៃផែនការសកម្មភាព និងយុទ្ធសាស្ត្រជាតិដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់

៣-ស្វែងរកការគាំទ្រ និងការចូលរួមពីគ្រប់មជ្ឈដ្ឋានក្នុងការអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ និងជំរុញអោយមានការ ចូលរួមពីស្ថាប័នរាជរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល សេវាឯកជន និងសហគមន៍ ដើម្បីអនុវត្តនូវច្បាប់ អនុក្រឹត្យ សារាចរណែនាំ និងការស្រាវជ្រាវសំរាប់ការអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ អោយមានប្រសិទ្ធភាព

៤-រៀបចំពិនិត្យ និងសំរេចនូវសារាចរ សេចក្តីសំរេចណែនាំ និងបទដ្ឋាននានា ស្តីពីការអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ សំរបសំរួលការរៀបចំផែនការសកម្មភាព និងយុទ្ធសាស្ត្រជាតិ សំរាប់អប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ដើម្បីសុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ

៥-រៀបចំនិងដាក់ស្នើជូនជាសេចក្តីព្រាងច្បាប់ អនុក្រឹត្យ និងគោលនយោបាយជាតិ ស្តីពីការអប់រំ និងកាត់បន្ថយការ ប្រើប្រាស់ថ្នាំជក់ ជាពិសេសច្បាប់ ឬ អនុក្រឹត្យ ស្តីពីការបង់ពន្ធដារ ការលក់រាយ ការផ្សព្វផ្សាយពាណិជ្ជកម្មការលើកកំពស់សុខភាព ការដាក់ផ្លាកលើផលិតផលថ្នាំជក់ និងការជក់នៅទីសាធារណៈ ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

**ប្រការ ៣ :**

បណ្តាសមាជិកគណៈកម្មការអន្តរក្រសួង តំណាងអោយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចូលរួមទទួលខុសត្រូវ ក្នុងក្របខ័ណ្ឌសមត្ថកិច្ច ភារកិច្ចដែលបានចែងក្នុងប្រការ២ខាងលើ និងត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីរាយការណ៍ពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

**ប្រការ ៤ :**

គណៈកម្មការអន្តរក្រសួងនេះ មានលេខាធិការដ្ឋានមួយ ដែលមានទីតាំងក្នុងក្រសួងសុខាភិបាល និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសុខាភិបាលដើម្បីសំរួលការងារ ។

**ប្រការ ៥ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីរដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម អស់លោក ជាគណៈកម្មការ ដូចប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

===

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០១

## សេចក្តីសំរេចលេខ ៣៦

## ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យ និងស្រាវជ្រាវករណីមិនប្រក្រតី ដែលពាក់ព័ន្ធទៅនឹងការអនុវត្តន៍ការងារជំរឿនមន្ត្រីរាជការ ជាពិសេសការអនុវត្តន៍តារាងទូទាត់បៀវត្សតាមប្រព័ន្ធពត៌មានវិទ្យា នៅក្រសួងសុខាភិបាល

--

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់ និង ជាបន្ទាន់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការត្រួតពិនិត្យ និងស្រាវជ្រាវករណីមិនប្រក្រតី ដែលពាក់ព័ន្ធទៅនឹងការអនុវត្តន៍ការងារជំរឿនមន្ត្រីរាជការ ជាពិសេសការអនុវត្តន៍តារាងទូទាត់បៀវត្សតាមប្រព័ន្ធពតិមានវិទ្យា នៅក្រសួងសុខាភិបាល ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **យឹន ចន** អគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ប្រធាន

២-លោក **ហេង ឆាំឆាន** ប្រធានក្រុមតំរោងតារាងទូទាត់បៀវត្ស អនុប្រធាន

៣-លោក **ជុក មុន្នី** តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សមាជិក

៤-លោក **ឌី ចំរើន** តំណាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច សមាជិក

៥-លោកស្រី **ឈាង ច័ន្ទតារា** តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៦-លោកវរសេនីយ៍ឯក **អ៊ុន បូរ៉ា** តំណាងអគ្គនាយកដ្ឋាននគរបាលជាតិ សមាជិក

៧-លោកវរៈសេនីយ៍ត្រី **គន្ធ ឈឿន** តំណាងអគ្គបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

៨-លោក **កែវ ធីវុធ** តំណាងលេខាធិការដ្ឋាន នៃអង្គភាពប្រឆាំងនឹងអំពើពុករលួយ សមាជិក

៩-លោក **គល់ សារមេត** មន្ត្រីលេខាធិការដ្ឋាន នៃអង្គភាពប្រឆាំងនឹងអំពើពុករលួយ លេខាកត់ត្រា

**ប្រការ ២ :**

គណៈកម្មការនេះ មានភារកិច្ច :

-ចុះត្រួតពិនិត្យ និងស្រាវជ្រាវករណីមិនប្រក្រតី ដែលពាក់ព័ន្ធទៅនឹងសកម្មភាពអនុវត្តការងារជំរឿនមន្ត្រីរាជការ ជាពិសេសការអនុវត្តន៍តារាងទូទាត់បៀវត្សតាមប្រព័ន្ធពត៌មានវិទ្យា នៅក្រសួងសុខាភិបាល ។

-ធ្វើរបាយការណ៍ ស្ដីពីលទ្ធផលនៃការត្រួតពិនិត្យករណីខាងលើនេះ ជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣ :** សមាជិកគណៈកម្មការទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គបញ្ជាការនៃអគ្គបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃ

ប្រទេស និងសមាសភាពដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតនេះទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

===

## III~ ការងារបណ្តាក្រសួង

## I~ទីស្តីការរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

### ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០១

**ប្រកាសលេខ ១៥៥ បទ.ប្រក**

**ស្តីអំពីការរៀបចំ និងការគ្រប់គ្រង**

**ប្រព័ន្ធ និងសេវាកម្ម អ៊ិនធឺណែត ( Internet ) និងប្រភេទសេវា VoIP**

**នៅព្រះរាជាណាចក្រកម្ពុជា**

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ. ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីប្រៃសណីយ៍ និងទូរគមនាគមន៍

-យោងតាមសេចក្តីសំរេចអង្គប្រជុំថ្នាក់ដឹកនាំ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០១

**សំរេច**

**ប្រការ ១ :** ការរៀបចំប្រព័ន្ធអ៊ិនធឺណែតណូដ ( Internet Node ) ឬប្រព័ន្ធដែលប្រើ ( Internet Protocol IP Based Network ) និងការបន្តភ្ជាប់រវាងប្រព័ន្ធទាំងនោះ ត្រូវមានច្បាប់អនុញ្ញាតពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

១.១/ អ៊ិនធឺណែតណូដ ( Internet Node ) ដែលមានមូលដ្ឋានបច្ចេកទេសក្នុងព្រះរាជាណាចក្រកម្ពុជា ចាំបាច់ត្រូវបានកំណត់នូវ IP Address របស់ប្រទេសកម្ពុជា ។

១.២/ អ៊ិនធឺណែតណូដ ( Internet Node ) ត្រូវបន្តភ្ជាប់គ្នា ( Peering ) ពីមួយទៅមួយតាមលក្ខណៈបច្ចេកទេសដែលកំណត់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

១.៣/ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានភារកិច្ច តម្លើង និងគ្រប់គ្រងបច្ចេកវិទ្យាភ្ជាប់ទូរស័ព្ទតាម អ៊ិនធឺណែត ( VoIP ) ។

**ប្រការ ២ :** ការធ្វើសេវាកម្ម និងការប្រើប្រាស់ទូរស័ព្ទតាមប្រព័ន្ធ អ៊ិនធឺណែត ( VoIp ) សំរាប់ភ្ជាប់សន្ទនាក្នុងប្រទេស និងអន្តរជាតិអាចប្រព្រឹត្តទៅបាន ស្របតាមប្រការ ១ ចំណុច ១.៣ ខាងលើ ។

**ប្រការ ៣ :** ត្រូវហាមឃាត់ជាដាច់ខាតនូវ :

៣.១/ការនាំចូល និងប្រើប្រាស់រាល់បរិក្ខារបច្ចេកទេសទាំងឡាយសំរាប់ធ្វើសេវាកម្ម ទូរស័ព្ទ (VoIP ) ទៅអន្តរជាតិដោយគ្មានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

៣.២/ ការផ្គត់ផ្គង់ ឬការប្រើប្រាស់បណ្ណអ៊ិនធឺណែត ( IP Cards ) និងបណ្ណស័ព្ទទាំងឡាយ **(Phone Coroig) ដែលផលិត ឬនាំចូលដោយគ្មានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ប្រការ ៤** : ប្រតិបត្តិករដែលបានទទួលអាជ្ញាប័ណ្ណផ្តល់សេវាកម្មអ៊ិនធឺណែត ( ISP ) ឬជនណាដែលមិនគោរពតាមបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវបញ្ឈប់សកម្មភាពជាបន្ទាន់ ។

បើសិនសកម្មភាពនោះនៅតែបន្ត ប្រតិបត្តិករ ឬជននោះត្រូវផ្តន្ទាទោសតាមច្បាប់ ។

**ប្រការ ៥** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦** : ខុទ្ទកាល័យ អធិការដ្ឋាន និងគ្រប់នាយកដ្ឋានក្រោមឱវាទក្រសួង មានភារកិច្ចអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ៧** : ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**សូ ឃុន**

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០១

## ប្រកាសលេខ ១៥៧ មទ.ប្រក

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីអំពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួង ប្រៃសណីយ៍ និងទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-យោងសារាចរណែនាំលេខ ១០ សរណន ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពី នីតិវិធីនៃការតែងតាំង មន្ត្រី រាជការស៊ីវិល របស់រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញលិខិតលេខ ១៥៩ មស.តត ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០១ របស់ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានឃើញការងារចាំបាច់របស់ក្រសួង

**សម្រេច**

**ប្រការ ១** : តែងតាំងលោក **លី គណារិទ្ធ** ជាប្រធាន បច្ចីវប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្តកណ្តាល ។

**ប្រការ ២** : មន្ត្រីរាជការ ដូចមានចែងក្នុង ប្រការ ១ ខាងលើ ត្រូវអនុវត្តន៍ តាមតួនាទី ភារកិច្ច និង សមត្ថកិច្ចរបស់ខ្លួន ។

**ប្រការ ៣** : ខុទ្ទកាល័យ . អធិការដ្ឋាន . គ្រប់នាយកដ្ឋាន ក្រោមឱវាទក្រសួង . គ្រប់មន្ទីរ ប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្ត ក្រុង និង សាមីខ្លួនត្រូវអនុវត្ត តាមខ្លឹមសារ នៃប្រកាសនេះ ។

**ប្រការ ៤** : រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥** : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**សូ ឃុន**

===

រាជធានីភ្នំពេញ . ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

## ប្រកាសលេខ ១៥៩ បទ.ប្រក

## ស្តីពីការ បង្កើតមជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និងប័ណ្ណស័ព្ទ

---

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួង ប្រៃសណីយ៍និងទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-យោងស្មារតីអង្គប្រជុំ ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០១

-យោងការងារចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១** : ត្រូវបានបង្កើតមជ្ឈមណ្ឌលមួយដែលមានឈ្មោះថា " **មជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និងប័ណ្ណស័ព្ទ** " ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស ។

**ប្រការ ២** : រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : ខុទ្ទកាល័យ , អធិការដ្ឋាន និង គ្រប់នាយកដ្ឋាន ក្រោមឱវាទក្រសួងត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារ នៃប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**សូរ ឃុន**

-✱-

## ២_ទីស្ដីការរដ្ឋមន្ត្រី ក្រសួងធម្មការនិងសាសនា

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០១

**សេចក្ដីសំរេច**

**សេចក្ដីសំរេចលេខ ១៦០ ធក សសរ**

**រដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ ស្ដីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងធម្មការ និងសាសនា

-យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ដ នៃនិកាយ "សេវែនដេយអាត់វែនទីស្ទ" នៅខេត្តសៀមរាប របស់លោក **វស់ សុជាតិ** អាយុ ៤២ ឆ្នាំ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០០

-យោងចំណារឯកភាព របស់សាលាខេត្តសៀមរាប លេខ ២០៨៥ ខសរ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០០

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយបើកសាខាការថ្វាយបង្គំសាសនាគ្រិស្ដ ឈ្មោះ " **សេវែនដេយអាត់វែនទីស្ទចំបក់ហែ** " មួយកន្លែងដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ ១៧៤២ ក្រុម ១៧ ភូមិចំបក់ហែ ឃុំពួក ស្រុកពួក ខេត្តសៀមរាប ។

**ប្រការ ២** : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ដ " សេវែនដេយអាត់វែនទីស្ទចំបក់ហែ " ត្រូវអនុញ្ញាតអោយប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ដ ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ ៣** : បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត " **សេទេនដោយអាត់ទេនទីស្ទចំបក់ហៃ** " ត្រូវគោរព និងអនុវត្តអោយបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទប្បញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាពនិងទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ ៤** : រាល់ការអនុវត្តន៍ទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៥** : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានធម្មការ " **នាយកដ្ឋានពាហិរសាសនា** " គ្រប់ស្ថាប័ន អង្គភាព ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៦** : សេចក្តីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ជា សាវឿន**

===

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

## សេចក្តីសំរេចលេខ ១៦១ ធក សសរ

## រដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងធម្មការ និងសាសនា

-យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃនិកាយ "សេវេនដេយអាត់វេនទីស្ទ" នៅខេត្តកោះកុង របស់លោក **ជួប សារឿន** អាយុ ២៨ ឆ្នាំ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០០

-យោងចំណារបញ្ជូន របស់សាលាខេត្តកោះកុង លេខ ៣១៤ ខកក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០០

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយបើកសាខាការថ្វាយបង្គំសាសនាគ្រិស្ត ឈ្មោះ " **សេវេនដេយអាត់វេនទីស្ទកោះកុង** " មួយកន្លែងដែលមានទីតាំងស្ថិតនៅ ភូមិ៣ ឃុំស្មាច់មានជ័យ ស្រុកស្មាច់មានជ័យ ខេត្តកោះកុង ។

**ប្រការ ២** : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត " សេវេនដេយអាត់វេនទីស្ទកោះកុង " ត្រូវអនុញ្ញាតអោយប្រើប្រាស់និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ ៣** : បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត " **សេវេនដេយអាត់វេនទីស្ទកោះកុង** " ត្រូវគោរពនិងអនុវត្តអោយបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទប្បញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាពនិងទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្ដាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ ៤** : រាល់ការអនុវត្តន៍ទាំងឡាយណា ដែលផ្ទុយពីសេចក្ដីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៥** : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានធម្មការ " **នាយកដ្ឋានពាហិរសាសនា** " គ្រប់ស្ថាប័ន អង្គភាព ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការណ៍អនុវត្តន៍សេចក្ដីសំរេចនេះ អោយមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ ៦** : សេចក្តីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ជា សាវឿន**

===

រាជធានីភ្នំពេញ . ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

## សេចក្តីសំរេចលេខ ១៦២ កធ សសរ

~

## រដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងធម្មការ និងសាសនា

-យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ នៃនិកាយ "សេវេនដេយអាត់វេនទីស្ទ" នៅខេត្តតាកែវ របស់លោក **សែម កុសល្យ** អាយុ ៣១ ឆ្នាំ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០០

-យោងចំណារបញ្ជូន របស់សាលាខេត្តតាកែវ លេខ ៣០៣ សបជ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០០

### សំរេច

**ប្រការ ១** : អនុញ្ញាតអោយបើកសាខាការថ្វាយបង្គំសាសនាគ្រិស្ត ឈ្មោះ " **សេវេនដេយអាត់វេនទីស្ទអង្គតាសោម**" មួយកន្លែងដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ ១១ ផ្លូវលេខ ៣ ក្រុម ២ ភូមិអង្គតាសោម ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ។

**ប្រការ ២** : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត " **សេវេនដេយអាត់វេនទីស្ទអន្តរាសោម** " ត្រូវអនុញ្ញាតអោយប្រើប្រាស់និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ ៣** : បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត " **សេវេនដេយអាត់វេនទីស្ទអន្តរាសោម** " ត្រូវគោរព និងអនុវត្តអោយបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទប្បញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាពនិងទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់ សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ ៤** : រាល់ការអនុវត្តន៍ទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៥** : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានធម្មការ " **នាយកដ្ឋានពាហិរសាសនា** " គ្រប់ស្ថាប័ន អង្គភាព ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៦** : សេចក្តីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ជា សាវឿន**

===

## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០១

**ប្រកាសលេខ ២០៤ ប្រក.សក.បធ**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

**រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ______

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រី រាជការស៊ីវិល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ បង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន

-បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

-យោងលិខិតលេខ ១៩៣ អគរ.ត.ត ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០១ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-យោងតាមការចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១** : តែងតាំងលោក **ណុប ហេង** ជានាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូនក្រុងព្រះសីហនុ នៃក្រសួងសាធារណការ និង ដឹកជញ្ជូន ។

**ប្រការ ២** : លោកនាយកខុទ្ទកាល័យ ឯកឧត្តម អគ្គនាយករដ្ឋបាល ឯកឧត្តម អគ្គនាយកសាធារណការ លោកនាយកមន្ទីរសាធារណការ និងដឹកជញ្ជូន ក្រុងព្រះសីហនុ ព្រមទាំងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តរៀង១ខ្លួន តាមខ្លឹមសារនៃប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

ហត្ថលេខា និងត្រា

**ឃឹម តាំងលឹម**

== ==

==

=